**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៖ ៥៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកំណត់តំបន់គ្រប់គ្រងជាតំបន់ប្រើប្រាស់ដោយចីរភាពលើផ្ទៃដីទំហំ ២៧៧ (ពីររយចិតសិបប្រាំពីរ)ហិកតា ស្ថិតនៅឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំត្បែង» ភូមិសាស្ត្រឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែប្រែឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម

- បានឃើញអនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់តំបន់គ្រប់គ្រងជាតំបន់ប្រើប្រាស់ដោយចីរភាព លើផ្ទៃដីទំហំ២៧៧( ពីររយចិតសិបប្រាំពីរ )ហិកតា នៃឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ភូមិសាស្ត្រឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប ដូចមានភ្ជាប់ក្នុងផែនទីនិងចំណុចនិយាមកាក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ផ្ទៃដីដូចមានកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវបន្តនីតិវិធីចុះបញ្ជីដីធ្លីជូនក្រសួងបរិស្ថានជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងប្រគល់សិទ្ធិជូនក្រសួងការពារជាតិដើម្បីប្រើប្រាស់ក្នុងវិស័យការពារជាតិ។

វិធាននៃការប្រើប្រាស់ទីតាំងផ្ទៃដីខាងលើ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**អ៊ាង សុផល្លែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០២៦

ផែនទីតំបន់ប្រើប្រាស់ដោយចីរភាព លើផ្ទៃដីទំហំ ២៧៧( ពីររយចិតសិបប្រាំពីរ )ហិកតា

នៃឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ភូមិសាស្ត្រឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប



ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០២៦
ចំណុចនិយាមកាតំបន់ប្រើប្រាស់ដោយចីរភាព លើផ្ទៃដីទំហំ ២៧៧(ពីររយចិតសិបប្រាំពីរ)ហិកតា
នៃឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ភូមិសាស្រ្តឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប

| និយាមកា (Datum: WGS 1984, Projection: UTM Zone 48N) | | | | | |
|---|---|---|---|---|---|
| ID | X | Y | ID | X | Y |
| 1 | 413820 | 1501085 | 24 | 416520 | 1500601 |
| 2 | 413851 | 1501177 | 25 | 416411 | 1500437 |
| 3 | 413928 | 1501318 | 26 | 416293 | 1500234 |
| 4 | 414050 | 1501471 | 27 | 416121 | 1500193 |
| 5 | 414122 | 1501547 | 28 | 415922 | 1500254 |
| 6 | 414227 | 1501632 | 29 | 415630 | 1500440 |
| 7 | 414361 | 1501680 | 30 | 415402 | 1500474 |
| 8 | 414480 | 1501692 | 31 | 415165 | 1500466 |
| 9 | 414584 | 1501688 | 32 | 415018 | 1500440 |
| 10 | 414752 | 1501705 | 33 | 414872 | 1500488 |
| 11 | 414928 | 1501744 | 34 | 414792 | 1500546 |
| 12 | 415079 | 1501767 | 35 | 414721 | 1500653 |
| 13 | 415223 | 1501774 | 36 | 414687 | 1500775 |
| 14 | 415361 | 1501766 | 37 | 414587 | 1500856 |
| 15 | 415545 | 1501723 | 38 | 414412 | 1500918 |
| 16 | 415745 | 1501661 | 39 | 414257 | 1500940 |
| 17 | 415890 | 1501566 | 40 | 414111 | 1500903 |
| 18 | 416013 | 1501479 | 41 | 414024 | 1500839 |
| 19 | 416241 | 1501320 | 42 | 413951 | 1500783 |
| 20 | 416386 | 1501151 | 43 | 413869 | 1500780 |
| 21 | 416517 | 1500971 | 44 | 413778 | 1500888 |
| 22 | 416560 | 1500872 | 45 | 413768 | 1500991 |
| 23 | 416547 | 1500726 | 46 | 413820 | 1501085 |